**ការកែសម្រួលទម្រង់ការធ្វើ តែស្ត កូវីដ និង ការឃាត់សិស្សទុកនៅផ្ទះ**

*សេចក្តីចំណាំទុកដ៏សំខាន់៖ នៅថ្ងៃសុក្រ ទី24 ខែកញ្ញា វេលាម៉ោង 4:30 ល្ងាច គឺនឹងមានក្រុមដឹកនាំ LBUSD ជួបជុំគ្នាសម្រាប់បើកការពិគ្រោះតាមរយៈ វិដេអូ ដើម្បីផ្តល់ជាការបង្ហាញកាន់តែច្រើនមកលើព័ត៌មានផ្នែកខាងក្រោម និង ដើម្បីដោះស្រាយជាមួយសំនួរខ្លះៗ ដែលយើងបានទទួលពីមាតាបិតា និង សមាជិកផ្សេងៗក្នុងសហគមន៍ ។ សូមបើកមើលតាម lbschools.net/youtube នៅពេលណាក៏បានបន្ទាប់ពីវេលាម៉ោង 4:30 ល្ងាច នៅថ្ងៃសុក្រ ទី24 ខែកញ្ញា ។*

ជម្រាបជូនសហគមន៍សាលារៀន ឡុងប៊ីច,

សម្រាប់យើងភាគច្រើន ថ្ងៃចន្ទ ទី27 ខែកញ្ញា នឹងស្ថិតនៅចំសប្តាហ៍ទី ប្រាំ នៃការផ្តើមឆ្នាំសិក្សា ។ ដោយមានជំនួយគាំទ្រពីលោកអ្នក យើងបានបើកសាលារៀនឡើងវិញ ប្រកបដោយជោគជ័យ ដើម្បីទទួលសិស្សចូលរៀនក្នុងថ្នាក់ផ្ទាល់សម្រាប់ឆមាសរដូវស្លឹកឈើធ្លាក់ ។ កាលពីពេលសប្តាហ៍កន្លងមក យើងបានជម្រាបជូនហើយថា យើងផ្អាកសិនអំពីការធ្វើ តែស្ត ជាលក្ខណៈមិនបង្ហាញរោគសញ្ញាទៅកាន់សិស្ស នៅពេលយើងធ្វើការវែកវែកមើលយ៉ាងដិតដល់អំពីទិន្នន័យ ។ យើងចង់បញ្ជាក់ថា LBUSD បានធ្វើការថ្លឹងថ្លែងស្មើមកលើចំណែកជាចម្បងខ្ពស់ជាងគេ គឺសុវត្ថិភាព និង ឧត្តមសិក្សាសម្រាប់សិក្សា ដោយយកចិត្តទុកដាក់ទាំងប្រយ័ត្នប្រយែង ដើម្បីឱ្យសិស្សភាគច្រើននៅតែអាចរៀនក្នុងថ្នាក់ផ្ទាល់បានជាដដែល ។ នៅពេលយើងបន្តការឃ្លាំមើលអំពីទិន្នន័យនៃជម្ងឺរាលដាល និង ក្បួនណែនាំពីក្រសួងសុខាភិបាល គឺយើងនឹងធ្វើការកែសម្រួលមកលើទម្រង់ការផ្នែកសុខភាព និង សុវត្ថិភាពរបស់យើង ដែលរាប់បញ្ចូលផងទាំងការកែសម្រួលធ្វើ តែស្ត កូវីដ ជាលក្ខណៈមិនបង្ហាញរោគសញ្ញាទៅកាន់ស៊ិស្ស និង ទម្រង់ការឃាត់សិស្សរបស់យើងទុកនៅផ្ទះ ។

**ការធ្វើ តែស្ត COVID-19 ទាំងព្រាវតាមលក្ខណៈមិនបង្ហាញជារោគសញ្ញា**

ក្នុងពេល បី សប្តាហ៍ដំបូងនៃឆ្នាំសិក្សា យើងបានធ្វើ តែស្ត ឱ្យបានច្រើនបំផុតទៅកាន់សិស្សមិនទាន់ចាក់ថ្នាំ វ៉ាក់ស៊ីន ។ យើងបានធ្វើ តែស្ត ប្រហែល 60,000 លើក ដែលបង្ហាញលទ្ធផល វិជ្ជមាន (Positive) ជាកម្រិតទាបក្រោម 1% ។ តាមពិតទៅ លទ្ធផល វិជ្ជមានប្រចាំសប្តាហ៍របស់យើងមានភាពចុះស្រករាល់សប្តាហ៍ ក្នុងរយៈពេល បី សប្តាហ៍ដំបូងនៃឆ្នាំសិក្សា ។ ម្តងទៀត នេះជាការបញ្ជាក់អំពីសេចក្តីយកចិត្តទុកដាក់នៃសិស្ស ក្រុមគ្រួសារ និង បុគ្គលិកសាលារៀនមកលើការធ្វើតាមទម្រង់ការផ្នែកសុខភាព និង សុវត្ថិភាព ។

ផ្តើមពីសប្តាហ៍ខាងមុខនេះទៅ **យើងនឹងធ្វើ តែស្ត ប្រចាំសប្តាហ៍ជាកម្រិត 10% ស្របតាមចំនួនសិស្សមិនទាន់ចាក់ថ្នាំ វ៉ាក់ស៊ីន នៅតាមសាលារៀននិមួយៗ** ។ ដូចជាការធ្វើ តែស្ត របស់យើងពីពេលកន្លងមកដែរ គឺយើងនឹងធ្វើ តែស្ត ដោយគ្មានការឈឺចាប់ទៅកាន់សិស្សតាមរយៈប្រើក្បួនត្បារច្រមុះដោយខ្លួនឯង ដែលសិស្សធ្លាប់បានធ្វើរួចហើយតាំងពីពេលសាលារៀនបើកឡើងវិញក្នុងខែមិនា ។ ក្រសួងអប់រំ ឌីស្ទ្រីគ នឹងបង្កើតជាបញ្ជីឈ្មោះទាំងព្រាវអំពីសិស្សទាំងអស់នេះរាល់សប្តាហ៍ ដោយប្រើម៉ាស៊ីនមិនបង្ហាញជាភាពលំអៀង ។ មធ្យោបាយសម្រាប់ធ្វើ តែស្ត ស្របតាមគំរូជាតំណាងភាពនឹងផ្តល់ឱកាសសម្រាប់យើងប្រមូលយកទិន្នន័យគួរទុកចិត្តបាន ដោយនៅពេលជាមួយគ្នាគឺជួយបន្ថយបន្ទុកអំពីការធ្វើ តែស្ត ក្នុងចំណោមសិស្ស និង សាលារៀន ។ មធ្យោបាយប្រើធ្វើ តែស្ត របៀបនេះ គឺមានភាពស្របតាមក្បួនណែនាំពីក្រសួងសុខាភិបាលជាតិសម្រាប់ការពារ COVID-19 ក្នុងសាលារៀន K-12 ។

**ការកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះ**

ការកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះ គឺជាមធ្យោបាយរក្សាទុកសិស្ស ដែលអាចមានការឆ្លងជម្ងឺ COVID-19 ឱ្យនៅតែចូលរៀនក្នុងថ្នាក់ផ្ទាល់ ។ ការសិក្សាស្រាវជ្រាវជាក្បួនវិទ្យាសាស្ត្រ និង បទពិសោធន៍ជុំវិញប្រទេសបានបង្ហាញមកថា នៅពេលណាក្រុមទាំង ពីរពាក់គម្របមុខក្នុងពេលកំពុងតែរៀន ដែលជាពេលអាចនាំមកការរាលដាលឆ្លង COVID-19 គឺវាមិនទំនងជាកើតឡើងទេ ហើយសិស្សអាចនៅតែបន្តការរៀនក្នុងថ្នាក់ផ្ទាល់បាន ប្រកបដោយសុវត្ថិភាព ឱ្យតែមានការធ្វើតាមទាំងប្រយ័ត្នប្រយែងយ៉ាងច្បាស់លាស់ ។

ក្នុងពេលកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះ គឺសិស្សនឹងត្រូវដកខ្លួនចេញពីកិច្ចការក្រៅផ្សេងៗ ដែលរាប់បញ្ចូលផងទាំងកីឡា និង កម្មវិធីច្រើនយ៉ាងក្នុងសហគមន៍ ។ ការធ្វើ តែស្ត ក្នុងពេលកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះ នឹងផ្តល់ជាស្រទាប់បន្ថែមមកលើសុវត្ថិភាព និង ការតាមដានមើល ។

**តើមានអ្វីកើតឡើងនៅពេលណាសិស្សទទួលការចាត់ទុកថា ទំនងជាអាចត្រូវបានឆ្លងជម្ងឺ ឬ នៅក្បែរមនុស្សមានជម្ងឺ?**
ចំពោះសិស្សចាក់ថ្នាំ វ៉ាក់សាំង ពេញកម្រិតហើយ គឺអាចបន្តការចូលរៀនក្នុងថ្នាក់ផ្ទាល់បាន ដោយនៅពេលជាមួយគ្នា គឺមានការឃ្លាំមើលរោគសញ្ញាចំនួន 14 ថ្ងៃ ។ បើសិនជាសិស្សមិនទាន់ចាក់ថ្នាំ វ៉ាក់សាំង ពេញកម្រិតនៅឡើយទេ ហើយទាំងសិស្ស ដែលទទួលការឆ្លងជម្ងឺ និង មនុស្សមានជម្ងឺស្រាប់បានពាក់គម្របមុខក្នុងកន្លែងសាលារៀន ដែលមានការមើលខុសត្រូវត្រឹមត្រូវ គឺសិស្ស ដែលទទួលការឆ្លងជម្ងឺនៅតែអាចចូលរៀនក្នុងថ្នាក់ផ្ទាល់បាន បើសិនជាគេ:

- គ្មានបង្ហាញជារោគសញ្ញា
- នៅតែបន្តការពាក់គម្របមុខ
- ទៅធ្វើ តែស្ត ចំនួន ពីរ លើកក្នុងរយៈពេលមួយសប្តាហ៍: មួយលើកភ្លាម បន្ទាប់ពីមាតាបិតាបានទទួលដំណឹងអំពីការចម្លងមេរោគ និង ម្តងទៀត ចំនួន បី ថ្ងៃបន្ទាប់ទៅ
- មិនចូលរួមក្នុងកិច្ចការក្រៅផ្សេងៗ ឬ កម្មវិធីច្រើនយ៉ាងក្នុងសហគមន៍ ដូចជា: កីឡា រហូតទាល់តែចំនួនពេលកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះនឹងបញ្ចប់ទៅ

**តើដល់ពេលណា និង តាមវិធីណា ទើបការកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះនឹងបញ្ចប់?**

មាន ពីរ ចំណែកសម្រាប់ពេលកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះនឹងបញ្ចប់:

1. បើសិនជាសិស្ស ដែលទទួលការឆ្លងជម្ងឺ មិនបង្ហាញជារោគសញ្ញានោះទេ ហើយការធ្វើ តែស្ត ទាំងអស់បញ្ជាក់ជាលទ្ធផលអវិជ្ជមាន សម្រាប់ COVID-19 ។ បន្ទាប់ទៅ ពេលសម្រាប់ការកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះនឹងបញ្ចប់នៅថ្ងៃប្រាំបី បន្ទាប់ពីថ្ងៃបានទទួលការចម្លង ។ យោងតាមលក្ខណនេះ គឺសិស្សនឹងទទួលការឃ្លាំមើលអំពីរោគសញ្ញាចំនួន 14 ថ្ងៃ បន្ទាប់ពីពេលបានទទួលការចម្លង ។
2. បើសិនជាសិស្ស ដែលបានទទួលការចម្លង ធ្វើ តែស្ត ទៅ និង បង្ហាញលទ្ធផលជា វិជ្ជមាន សម្រាប់ COVID-19 ឬ បង្ហាញជារោគសញ្ញា គឺសិស្សនឹងត្រូវសម្រាកនៅផ្ទះ និង ដកខ្លួននៅដាច់ពីមនុស្សផ្សេងៗក្នុងផ្ទះឱ្យបានចំនួន 10 ថ្ងៃ ឬ រហូតទាល់តែរោគសញ្ញារបស់គេមានភាពធូរឡើងវិញ ហើយគេគ្មានជម្ងឺគ្រុនក្នុងរយៈពេល 24 ម៉ោង ដោយមិនប្រើថ្នាំ ។

ការកែសម្រួលទម្រង់ការឃាត់សិស្សទុកនៅផ្ទះ នៅពេលណាចាំបាច់ រួមដោយការធ្វើ តែស្ត ទាំងព្រាវជាលក្ខណៈមិនបង្ហាញរោគសញ្ញាទៅកាន់សិស្ស គឺជាមធ្យោបាយត្រឹមតែ ពីរ យ៉ាងប៉ុណ្ណោះក្នុងចំណោមច្រើនយ៉ាងទៀតសម្រាប់បន្តការស្ទង់វាស់មកលើសុខភាព និង សុវត្ថិភាព ដែលរាប់បញ្ចូលផងទាំងការចាក់ថ្នាំ វ៉ាក់សាំង ទៅកាន់សិស្ស ស្របតាមលក្ខណអាចទទួលបាន ការពាក់គម្របមុខ ការប្រើម៉ាស៊ីនងាយបញ្ចេញខ្យល់ចេញចូល ការពិនិត្យសុខភាពអំពីរោគសញ្ញានៅឯផ្ទះ ការជូតសំអាតដៃ និង ការនៅដាច់ៗពីគ្នា ពេលអាចធ្វើបាន ។

សូមអរគុណចំពោះជំនួយគាំទ្រមកលើការប្រឹងប្រែងរបស់យើង នៅពេលយើងនៅតែបន្តការផ្តល់កម្មវិធីរៀនក្នុងថ្នាក់ផ្ទាល់ ស្របដោយសុវត្ថិភាព ដែលយើងទាំងអស់ដឹងថា ជាសារសំខាន់ណាស់សម្រាប់ភាពបណ្តុះបណ្តាល និង ភាពលូតលាស់ទៅកាន់សិស្សរបស់យើង ។

ដោយសេចក្តីអំណរគុណយ៉ាងជ្រៅជ្រះ,
Jill

Jill A. Baker, Ed. D.
អគ្គនាយកសាលារៀន